# ព្រះរាជក្រម

នស/រកម/០២១១/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៣/០០១/២០១១ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :



ROYAUME DU CAMBODGE ROYAL

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ សមាជរដ្ឋសភានិងព្រឹទ្ធសភា

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.—**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ស្របតាមមាត្រា ១១៦ថ្មី និងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.—**

សមាជរដ្ឋសភានិងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នានៃសមាជិករដ្ឋសភានិងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់ ។

បន្ទាប់ទៅនេះ សមាជរដ្ឋសភានិងព្រឹទ្ធសភា ត្រូវកំណត់ហៅថា សមាជ ។

**មាត្រា ៣.—**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិមាន :

- ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដី ឬ
- ករណីប្រធានសក្តិ បណ្តាលឲ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ជាតិ និងប្រជាជន ឬ
- ករណីផ្សេងៗទៀត ដែលគណៈកម្មាធិការសមាជយល់ឃើញថា ជាបញ្ហាសំខាន់របស់ប្រទេសជាតិ ។

# ជំពូកទី ២
# ការរៀបចំសមាជ

**មាត្រា ៤.—**

ប្រធានព្រឹទ្ធសភា ជាប្រធានសមាជ ។

ក្នុងករណីប្រធានសមាជអវត្តមាន ឬ មានធុរៈមិនអាចបំពេញមុខងារបាន ប្រធានរដ្ឋសភាត្រូវទទួលភារកិច្ចជំនួស ។

តំណែងជំនួសប្រធានសមាជ ដូចមានចែងខាងលើនេះ អាចនឹងផ្ទេរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ:

- អនុប្រធានទី១ ព្រឹទ្ធសភា
- អនុប្រធានទី១ រដ្ឋសភា

- អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី២ រដ្ឋសភា ។

**មាត្រា ៥.-**

សមាជ ត្រូវធ្វើជាសាធារណៈ នៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

**មាត្រា ៦.-**

សមាជ មានគណៈកម្មាធិការសមាជមួយជាអ្នករៀបចំសមាជ ។

សមាសភាពគណៈកម្មាធិការសមាជមានដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២- ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣- អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |
| ៤- អនុប្រធានទី១ រដ្ឋសភា | សមាជិក |
| ៥- អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦- អនុប្រធានទី២ រដ្ឋសភា | សមាជិក ។ |

ប្រធានគណៈកម្មការទាំងអស់នៃព្រឹទ្ធសភានិងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**មាត្រា ៧.-**

ប្រធានសមាជមានមុខងារដូចតទៅ:

ក- ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវ តាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន

ខ- ដឹកនាំអង្គប្រជុំនៃសមាជ

គ- បើក និង លើកពេលប្រជុំនៃសមាជ

ឃ- ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំសមាជ

ង- ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជ

ច- រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ

ឆ- ជាតំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។

**មាត្រា ៩.-**

រាល់ការចំណាយសម្រាប់ដំណើរការសមាជ ជាបន្ទុករបស់រដ្ឋសភា ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃសមាជ

**មាត្រា ១០.-**

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី អាចផ្តួចផ្តើមឲ្យមានការប្រជុំសមាជបាន ។

ប្រធានសមាជ អញ្ជើញសមាជិករដ្ឋសភា និងព្រឹទ្ធសភាឲ្យចូលរួមប្រជុំសមាជ ។

**មាត្រា ១១.-**

ការប្រជុំសមាជនឹងយកជាការបាន លុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់សមាជ មានតម្លៃជាសេចក្តីសម្រេចខ្ពស់បំផុតរបស់ប្រជាជាតិ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ និងចុះក្នុងរាជកិច្ច ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

សមាជប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរ ក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បីពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាតនៃ

ចំនួនសមាជិករដ្ឋសភាទាំងមូល និងដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងដំណើរការនៃកិច្ចប្រជុំសមាជលើកដំបូងនេះ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវយកមកអនុវត្ត រហូតដល់សមាជអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនបាន ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០២១១.១៧៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ: ១៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន